ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ទីស្តីការគណៈរដ្ឋមន្ត្រី

ឆ្នាំទី ០៥ លេខ ០២

# ព្រឹត្តិបត្រព័ត៌មាន

## ក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌

# សកម្មភាព ការងារ

ECOSOCC



ក ស វ

# Work Activities

ប្រចាំខែកុម្ភៈ ឆ្នាំ២០១២



# មាតិកាអត្ថបទ

## កិច្ចប្រជុំជំនាញបច្ចេកទេស រវាងក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ ក្រុមប្រឹក្សាអ្នកច្បាប់ និងតំណាងអគ្គលេខាធិការរាជរដ្ឋាភិបាល


| ល.រ | ឈ្មោះអត្ថបទ | លេខទំព័រ |
|---|---|---|
| ១- | សេចក្តីព្រាងព្រះរាជក្រឹត្យស្តីពីការផ្តល់ឋានៈសាស្ត្រាចារ្យ | ១ |
| ២- | សេចក្តីព្រាងព្រះរាជក្រឹត្យស្តីពីការបង្កើតគណៈកម្មាធិការជាតិគាំពារនិងអភិវឌ្ឍកុមារតូច | ២ |
| ៣- | ស្ថានភាពសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌កម្ពុជាប្រចាំឆ្នាំ២០១១ | ៤ |
| ៤- | សកម្មភាពដទៃទៀតរបស់ក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ | ១២ |

## សេចក្តីព្រាងព្រះរាជក្រឹត្យស្តីពី

# ការផ្តល់ឋានៈសាស្ត្រាចារ្យ



កាលពីថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០១២ វេលាម៉ោង ៨:៣០នាទី និងម៉ោង១៥:០០នាទី នៅទីស្តីការគណៈ-រដ្ឋមន្ត្រីមានបើកអង្គប្រជុំជំនាញបច្ចេកទេស ក្រោមអធិ-បតីភាព ឯកឧត្តម **យឹម ណុលសន** អនុប្រធាន ក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ ( ECOSOCC ) និង ឯកឧត្តម **ប្រាក់ សិទ្ធិ** សមាជិកក្រុមប្រឹក្សា អ្នកច្បាប់ ជាសហប្រធានអង្គប្រជុំ ដើម្បីពិនិត្យពិភាក្សា លើសេចក្តីព្រាងព្រះរាជក្រឹត្យស្តីពីការផ្តល់ឋានៈសាស្ត្រា-ចារ្យ ដោយមានការអញ្ជើញចូលរួមពីសំណាក់ សមាជិក អគ្គលេខាធិការរង និងមន្ត្រីនៃក.ស.វ. សមាជិក និងមន្ត្រី នៃក្រុមប្រឹក្សាអ្នកច្បាប់ តំណាងទីស្តីការគណៈរដ្ឋមន្ត្រី តំណាងអគ្គលេខាធិការរាជរដ្ឋាភិបាល តំណាងខុទ្ទកាល័យឧបនាយក រដ្ឋមន្ត្រី **សុខ អាន** មន្ត្រីជំនាញនៃទីស្តីការគណៈរដ្ឋមន្ត្រី និងតំណាងក្រសួងអប់រំ យុវជន និងកីឡា។

សូមរំឭកថា កន្លងមក ក្រសួងអប់រំ យុវជន និងកីឡាបានរៀបចំសេចក្តីព្រាងអនុក្រឹត្យស្តីពីការផ្តល់ឋានៈសាស្ត្រាចារ្យ ដែលត្រូវបានដាក់ឆ្លងអង្គប្រជុំជំនាញបច្ចេកទេសនៃទីស្តីការគណៈរដ្ឋមន្ត្រី នៅថ្ងៃទី១៨ ខែវិច្ឆិកា ឆ្នាំ២០១១។ សូមបញ្ជាក់ថា សេចក្តីព្រាងអនុក្រឹត្យនេះ មានវិសាលភាពគ្របដណ្តប់តែគ្រឹះស្ថានឧត្តមសិក្សាដែលនៅក្រោមការគ្រប់គ្រងរបស់ក្រសួងអប់រំ យុវជន និងកីឡាតែប៉ុណ្ណោះ តាមលំនាំអនុក្រឹត្យស្តីពីការផ្តល់ឋានៈសាស្ត្រាចារ្យក្នុងវិស័យសុខាភិបាល និងអនុក្រឹត្យស្តីពីការ ផ្តល់ឋានៈសាស្ត្រាចារ្យក្នុងវិស័យកសិកម្មដែលចេញរួចហើយ។ ចំពោះសេចក្តីព្រាងអនុក្រឹត្យនេះ អង្គប្រជុំបានផ្លាស់ប្តូរយោ-បល់យ៉ាងច្រើន ដោយផ្អែកលើច្បាប់ស្តីពីការអប់រំ ត្រង់វិសាលភាពគ្រប់គ្រងផង និងពិនិត្យលទ្ធភាពអនុវត្តអនុក្រឹត្យទាំងពីរ ដែលចេញហើយផង។ អង្គប្រជុំពេលនោះបានឯកភាពគ្នា និងសម្រេចបង្កើតក្រុមការងារមួយមានសមាសភាព ECOSOCC ក្រុមប្រឹក្សាអ្នកច្បាប់ និងតំណាងក្រសួងសាមី ដើម្បីរៀបចំសេចក្តីព្រាងព្រះរាជក្រឹត្យមួយថ្មីដែលជាឆ័ត្រមួយតែមួយក្នុងការផ្តល់ ឋានៈសាស្ត្រាចារ្យសម្រាប់គ្រប់វិស័យ ដោយជៀសវាងការបង្កើតអនុក្រឹត្យស្តីពីការផ្តល់ឋានៈសាស្ត្រាចារ្យចេញមកដដែលៗ តាមវិស័យដោយឡែកពីគ្នាតទៅទៀត។

អង្គប្រជុំជំនាញបច្ចេកទេសបានពិនិត្យពិភាក្សាលើសេចក្តីព្រាងព្រះរាជក្រឹត្យថ្មីនេះ ដែលក្រុមការងារបានរៀបចំ ហើយ បានសម្រេចកែសម្រួលទម្រង់និងខ្លឹមសារខ្លះៗ ពាក្យពេចន៍ និងឃ្លាប្រយោគមួយចំនួន ដើម្បីធ្វើឲ្យសេចក្តីព្រាងនេះកាន់ តែល្អ។

អង្គប្រជុំជំនាញបច្ចេកទេសបានបញ្ចប់កិច្ចពិភាក្សាលើសេចក្តីព្រាងនេះទាំងស្រុង។

## សេចក្តីព្រាងព្រះរាជក្រឹត្យស្តីពី

# ការបង្កើតគណៈកម្មាធិការជាតិគាំពារ និងអភិវឌ្ឍកុមារតូច

កាលពីថ្ងៃទី២២ និងថ្ងៃទី២៣ ខែកុម្ភៈ ឆ្នាំ២០១២ វេលាម៉ោង៨:៣០នាទី និងម៉ោង១៥:០០នាទី នៅទីស្តីការគណៈ-រដ្ឋមន្ត្រី មានបើកអង្គប្រជុំជំនាញបច្ចេកទេស ក្រោមអធិបតីភាពឯកឧត្តម **យឹម ណុលសន** អនុប្រធានក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ (ECOSOCC) និង ឯកឧត្តម **សុភ ផេង** សមាជិកក្រុមប្រឹក្សាអ្នកច្បាប់ ជាសហប្រធានអង្គប្រជុំ ដើម្បីពិនិត្យពិភាក្សាលើសេចក្តីព្រាងព្រះរាជក្រឹត្យស្តីពីការបង្កើតគណៈកម្មាធិការជាតិគាំពារនិងអភិវឌ្ឍកុមារតូច ដោយមានការអញ្ជើញចូលរួមពីសំណាក់ សមាជិក អគ្គលេខាធិការរង និងមន្ត្រី នៃក.ស.វ. សមាជិក និងមន្ត្រីនៃក្រុមប្រឹក្សាអ្នកច្បាប់ តំណាងទីស្តីការ គណៈរដ្ឋមន្ត្រី តំណាងអគ្គលេខាធិការរាជរដ្ឋាភិបាល តំណាងខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី **សុខ អាន** មន្ត្រីជំនាញនៃទីស្តីការគណៈរដ្ឋមន្ត្រី និងតំណាងក្រសួងអប់រំ យុវជន និងកីឡា។



អនុវត្តតាមគោលនយោបាយកំណែទម្រង់វិស័យអប់រំដែលឆ្លើយតបនឹងយុទ្ធសាស្រ្តចតុកោណរបស់រាជរដ្ឋាភិបាល ក្រសួងអប់រំ យុវជន និងកីឡា បានរៀបចំច្បាប់ស្តីពីការអប់រំដែលប្រកាសឲ្យប្រើតាមព្រះរាជក្រម នស/រកម/១២០៧/០៣២ ចុះថ្ងៃទី៨ ខែធ្នូ ឆ្នាំ២០០៧ បន្ទាប់មកក្រសួងបានរៀបចំផែនការកសាងលិខិតបទដ្ឋានគតិយុត្ត និងគោលនយោបាយនានា ក្នុងនោះមានគោលនយោបាយជាតិគាំពារនិងអភិវឌ្ឍកុមារតូច។ ដើម្បីអនុវត្តគោលនយោបាយជាតិនេះឲ្យមានប្រសិទ្ធភាព ចាំបាច់ត្រូវមានព្រះរាជក្រឹត្យបង្កើតគណៈកម្មាធិការជាតិគាំពារនិងអភិវឌ្ឍកុមារតូច។

យោងតាមស្មារតីនេះ ក្រសួងអប់រំ យុវជន និងកីឡា បានរៀបចំសេចក្តីព្រាងចំនួនពីរគឺ សេចក្តីព្រាងព្រះរាជក្រឹត្យស្តីពីការបង្កើតគណៈកម្មាធិការជាតិគាំពារនិងអភិវឌ្ឍកុមារតូច និងសេចក្តីព្រាងអនុក្រឹត្យស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈកម្មាធិការជាតិគាំពារ និងអភិវឌ្ឍកុមារតូច ក្នុងគោលបំណងអនុវត្តគោលនយោបាយឲ្យសម្រេច ដោយពង្រីកការផ្តល់សេវាគាំពារនិងអភិវឌ្ឍកុមារតូច និងពង្រឹងគុណភាពនៃការផ្តល់សេវា ដែលឆ្លើយតបទៅនឹងយុទ្ធសាស្រ្តនានានៃគោលនយោ-

បាយជាតិ ព្រមទាំងកំណត់បានពីការទទួលខុសត្រូវរបស់ក្រសួង និងស្ថាប័នពាក់ព័ន្ធ និងដើម្បីឆ្លើយតបទៅនឹងរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជាដែលមានចែងក្នុងមាត្រា៤៧ មាត្រា៤៨ មាត្រា៦៥ និងមាត្រា៧៣ និងសន្ធិសញ្ញាស្តីពីសិទ្ធិកុមារ អនុសញ្ញានៃការលុបបំបាត់រាល់ទម្រង់នៃការរើសអើងប្រឆាំងនឹងស្ត្រីភេទ ជាពិសេសច្បាប់ស្តីពីការអប់រំ មាត្រា១៦ ចែងថា “ រដ្ឋត្រូវគាំពារនិងអប់រំកុមារតូចចាប់ពីកម្រិតសូន្យឆ្នាំមុនមត្តេយ្យសិក្សា ដែលជាទូទៅប្រព្រឹត្តនៅទារកដ្ឋាន នៅសហគមន៍ ឬនៅផ្ទះ។ ការអប់រំនៅមត្តេយ្យសិក្សាត្រូវចាប់ផ្តើមមុនបឋមសិក្សា ដើម្បីត្រៀមលក្ខណៈចូលរៀនបឋមសិក្សា។ ក្រសួងទទួលបន្ទុកវិស័យអប់រំ និងក្រសួង ស្ថាប័នពាក់ព័ន្ធ ត្រូវកំណត់ខ្លឹមសារស្តីពីការគាំពារនិងអប់រំកុមារតូច ” [១]។




អង្គប្រជុំជំនាញបច្ចេកទេសបានពិនិត្យពិភាក្សាលើសេចក្តីព្រាងព្រះរាជក្រឹត្យស្តីពីការបង្កើតគណៈកម្មាធិការជាតិគាំពារនិងអភិវឌ្ឍកុមារតូច ហើយបានសម្រេចកែសម្រួល ទម្រង់ ខ្លឹមសារ ពាក្យពេចន៍ និងឃ្លាប្រយោគ ដើម្បីធ្វើឲ្យសេចក្តីព្រាងនេះកាន់តែល្អ ហើយបានបន្តពិនិត្យពិភាក្សាលើសេចក្តីព្រាងអនុក្រឹត្យស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់អគ្គលេខាធិការដ្ឋាននៃគណៈកម្មាធិការជាតិគាំពារនិងអភិវឌ្ឍកុមារតូចរហូតដល់ចប់ ដោយមានការកែសម្រួលមួយចំនួន។ អង្គប្រជុំជំនាញបច្ចេកទេសបានបញ្ចប់ការពិភាក្សាលើសេចក្តីព្រាងនេះទាំងស្រុង។

---

(១) អត្ថបទនេះដកស្រង់ពីសេចក្តីព្រាងសេចក្តីថ្លែងហេតុនៃសេចក្តីព្រាងព្រះរាជក្រឹត្យស្តីពីការបង្កើតគណៈកម្មាធិការជាតិគាំពារនិងអភិវឌ្ឍកុមារតូច។

# ស្ថានភាពសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌កម្ពុជា ប្រចាំឆ្នាំ២០១១



របាយការណ៍នៃស្ថានភាពសេដ្ឋកិច្ចសង្គមកិច្ចនិងវប្បធម៌កម្ពុជា សម្រាប់ឆ្នាំ២០១១នេះ ជាលទ្ធផលនៃកិច្ចប្រជុំទូលាយក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ នាថ្ងៃទី០១ ខែមីនា ឆ្នាំ២០១២ ដែលដឹកនាំដោយឯកឧត្តម **យឹម ឆាយលី** ទេសរដ្ឋមន្ត្រីទទួលបន្ទុកបេសកកម្មពិសេស ប្រធានក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ ដោយមានការអញ្ជើញចូលរួមពីសំណាក់ សមាជិក-សមាជិកា អគ្គលេខាធិការ អគ្គលេខាធិការរង មន្ត្រី ក.ស.វ. និងតំណាងក្រសួង-ស្ថាប័នពាក់ព័ន្ធ។

សេដ្ឋកិច្ច-សង្គមកិច្ចកម្ពុជាក្នុងឆ្នាំ២០១១ បានជួបនឹងការលំបាកមួយចំនួនដូចជាគ្រោះទឹកជំនន់ ការឡើងថ្លៃទំនិញ ជាពិសេសប្រេងឥន្ធនៈ និងម្ហូបអាហារនៅក្នុងត្រីមាសទីពីរ និងទីបី។ សាកលភាវូបនីយកម្ម នាសម័យបច្ចុប្បន្នធ្វើឲ្យសេដ្ឋកិច្ច-សង្គមកិច្ចកម្ពុជារងឥទ្ធិពលផងដែរពីសេដ្ឋកិច្ចសកលលោក។ លំហូរវិនិយោគ អត្រាការប្រាក់ អត្រាប្តូរប្រាក់ ការនាំចេញ-នាំចូល សកម្មភាពវិស័យសំណង់ ទេសចរណ៍ និងផលិតកម្មផ្សេងៗ សុទ្ធតែពឹងផ្អែកលើលក្ខខណ្ឌនៃសេដ្ឋកិច្ចអន្តរជាតិ។ ទោះបីជាសេដ្ឋកិច្ចសកលលោកមានការងើបឡើងវិញខ្លះពីវិបត្តិហិរញ្ញវត្ថុក៏ដោយ ក៏នៅតែមានអស្ថេរភាពមួយចំនួន ដែលជាឧបសគ្គនៃការលូតលាស់ក្នុងឆ្នាំ២០១១ ជាសាកល ក៏ដូចជានៅកម្ពុជា។ ក្នុងនោះមាន វិបត្តិបំណុលនៃសហភាពអឺរ៉ុប ភាពមិននឹងនរនៃប្រាក់ដុល្លារ និងប្រាក់អឺរ៉ូជាដើម។

ក្នុងឆ្នាំ២០១១ យើងសង្កេតឃើញថា ព្រះរាជាណាចក្រកម្ពុជា បើធៀបនឹងឆ្នាំមុនៗបន្ទាប់ពីវិបត្តិមានការងើបឡើងវិញនៃលំហូរវិនិយោគបរទេស ការនាំចេញវាយនភណ្ឌ និងវិស័យសំណង់។ ទេសចរណ៍ និងកសិកម្ម ជាវិស័យគន្លឹះពីរដែលរួមចំណែកយ៉ាងធំក្នុងសេដ្ឋកិច្ចជាតិ និងក៏បង្ហាញអំពីនិរន្តរភាពនៃការរីកចម្រើនរបស់ខ្លួនផងដែរ ទោះបីក្នុងលក្ខខណ្ឌវិបត្តិក្តី ឬគ្រោះធម្មជាតិក្តី។ អតិផរណាមានការចុះវិញខ្លះនៅក្នុងត្រីមាសទីបួន ដែលធ្វើឲ្យអតិផរណាមធ្យមប្រចាំឆ្នាំ២០១១ ស្ថិតក្នុងកម្រិតសមរម្យ។

## ១) ស្ថានភាពសន្ទស្សន៍ថ្លៃទំនិញប្រើប្រាស់ និងអត្រាប្តូរប្រាក់

•អតិផរណានៅព្រះរាជាណាចក្រកម្ពុជាក្នុងឆ្នាំ ២០១១ មានអត្រាស្មើនឹង ៥,៥%។ *តារាងខាងក្រោមបង្ហាញតួលេខអតិផរណានៃខែនិមួយៗ ក្នុងឆ្នាំ ២០១១* (ដែលជាការឡើងនៃថ្លៃទំនិញធៀបនឹងខែដូចគ្នាឆ្នាំមុន)។

| | ធៀបនឹង... | មករា | កុម្ភៈ | មីនា | មេសា | ឧសភា | មិថុនា | កក្កដា | សីហា | កញ្ញា | តុលា | វិច្ឆិកា | ធ្នូ | ប្រចាំឆ្នាំ |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| ២០១១ | ខែដូចគ្នាឆ្នាំមុន | ៣,៣% | ៣,៨% | ៣,៨% | ៥,២% | ៦,៥% | ៧,១% | ៧,១% | ៦,៤% | ៦,៧ | ៥,៣ | ៥,៦ | ៤,៩ | ៥,៥% |
| ២០១០ | ខែដូចគ្នាឆ្នាំមុន | ៦,៩% | ៧,៣% | ៦,៧% | ៥,៣% | ៤,៥% | ២,៥% | ១,៦% | ១,៧% | ១,៩% | ៣,៦% | ៣,២% | ៧,៣% | ៤% |
| ២០០៩ | ខែដូចគ្នាឆ្នាំមុន | ៨,០% | ៦,២% | -០,៧% | -៣,៩% | -៥,៧% | -៤,៨% | -៣,៩% | -២,៩% | -២,៣% | -១,៥% | ១,៣% | ៨,០% | –០,៧% |

• បើពិនិត្យក្រុមទំនិញនីមួយៗ ការប្រៀបធៀបឆ្នាំ២០១១/២០១០ បង្ហាញបម្រែបម្រួលសន្ទស្សន៍ថ្លៃដូចខាងក្រោម៖

| ល.រ. | ក្រុមទំនិញ | បម្រែបម្រួលសន្ទស្សន៍ថ្លៃ | អត្រារួមចំណែក |
|---|---|---|---|
| ០ | ទំនិញប្រើប្រាស់គ្រប់មុខ (២៥៩ មុខ) | ៥,៥% | ១០០% |
| ១ | ម្ហូបអាហារ និងភេសជ្ជៈមិនមែនជាតិស្រវឹង | ៦,៥% | ៥៣% |
| | ក្នុងនោះ៖ ម្ហូបអាហារ | ៦,៦% | ៥២% |
| ២ | ភេសជ្ជៈមានជាតិស្រវឹង និងថ្នាំជក់ | ០,១% | ០% |
| ៣ | សម្លៀកបំពាក់ និងស្បែកជើង | ២,៤% | ១,៣% |
| ៤ | ផ្ទះសំបែង ទឹក អគ្គិសនី ឧស្ម័ន និងឥន្ធនៈផ្សេងទៀត | ៣,៨% | ១២% |
| | ក្នុងនោះ៖ ឧស្ម័ន | ១៦% | ៨% |
| ៥ | គ្រឿងសង្ហារិម និងសម្ភារៈប្រើប្រាស់ | ១,៩% | ១% |
| ៦ | សុខាភិបាល | ០,៨% | ០,៧% |
| ៧ | ការដឹកជញ្ជូន | ៧,១% | ១៦% |
| | ក្នុងនោះ៖ សាំង | ១៦% | ១៤% |
| ៨ | ទូរគមនាគមន៍ | ០,៨% | ០,២% |
| ៩ | ការកម្សាន្ត និងវប្បធម៌ | -១,៦% | -០,៨% |
| ១០ | ការសិក្សា | ០,៦% | ០,១% |
| ១១ | ភោជនីយដ្ឋាន | ៧,៩% | ៨% |
| ១២ | ទំនិញ និងសេវាកម្មផ្សេងទៀត | ៩,៣% | ៣,៩% |

➤ ដូច្នេះការរួមចំណែកសំខាន់ៗក្នុងអតិផរណាឆ្នាំ២០១១មាន៖ ក្រុមម្ហូបអាហារ ៥២% ផ្ទះសំបែង ទឹក អគ្គិសនី ឧស្ម័ន និងឥន្ធនៈផ្សេងទៀត ១២% ការដឹកជញ្ជូន ១៦% និងភោជនីយដ្ឋាន ៨%។

➤ មុខទំនិញដែលមានការឡើងថ្លៃគួរឲ្យកត់សម្គាល់មានសាច់ជ្រូក ១៦% សាច់គោស្រស់ ៩,២% ផ្លែឈើ ១០% ឧស្ម័ន ១៦% ប្រេងសាំង ១៦% និងម៉ាស៊ូត ២២% ។

➤អង្ករជាមុខទំនិញយ៉ាងសំខាន់សម្រាប់ប្រជាជនកម្ពុជា ដែលមានការឡើងថ្លៃតែ ០,៩% ប៉ុណ្ណោះ។

**•អត្រាប្តូរប្រាក់៖**

➤ ជារួមអត្រាប្តូរប្រាក់រៀល/ដុល្លារ មានស្ថេរភាព។ បើប្រៀបធៀបឆ្នាំ ២០១១|២០១០ យើងសង្កេតឃើញថា៖

▪ ប្រាក់រៀលឡើងថ្លៃ០,៣% ធៀបនឹងដុល្លារសហរដ្ឋអាមេរិក

▪ ប្រាក់រៀលឡើងថ្លៃ ៥,២% ធៀបនឹងបាតថៃ

▪ ប្រាក់រៀលឡើងថ្លៃ ៧,៧% ធៀបនឹងដុងវៀតណាម។

## ២) ស្ថានភាពថវិកាជាតិ

• យោងតាមស្ថិតិដែលឆ្លងកាត់រតនាគារជាតិ ចំណូលថវិកាជាតិក្នុងឆ្នាំ២០១១នេះ អនុវត្តបានចំនួន ៦ ៤៣៤ ពាន់លានរៀល ស្មើនឹង ៩៣% នៃគម្រោង ក្នុងនោះ៖ ចំណូលមូលធនអនុវត្តបាន ២៩៤ពាន់លានរៀល ស្មើនឹង ៧៤% នៃគម្រោង និងចំណូលចរន្ត ៦ ១៣៩ ពាន់លានរៀល ស្មើនឹង ៩៤% នៃគម្រោង។

• បើធៀបនឹងឆ្នាំ ២០១០ ចំណូលថវិកាជាតិកើនឡើង ៧% ដែលក្នុងនោះ ចំណូលចរន្តកើនឡើង ៧%ប៉ុន្តែចំណូលមូលធនថយចុះ ១%។

▪ ការកើនឡើងនៃចំណូលចរន្ត ជាចម្បងដោយសារតែចំណូលសារពើពន្ធកើនឡើង ១២%។

| មុខចំណូល | អនុវត្ត គម្រោង | %∆ធៀបនឹង ឆ្នាំ២០១០ |
|---|---|---|
| **ចំណូលសារពើពន្ធ** | ៩៦% | +១២% |
| ✓**ពន្ធ និងអាករគយ** | ១១៣% | +១១% |
| –ពន្ធគយ (របបនាំចូល) | ៩៤% | -២% |
| –អាករពិសេសលើរបបនាំចូល | ១០៦% | +១០% |
| –អាករលើតម្លៃបន្ថែមរបបនាំចូល | ១៣២% | +២៩% |
| –អាករនាំចេញ | ៥៦៩% | +២០៣% |
| –អាករបន្ថែមលើផលិផលតេលសិលា | ៩៨% | -២% |
| ✓**ចំណូលពន្ធដារ** | ៨៨% | +១៣% |
| –ពន្ធលើប្រាក់បៀវត្ស | ៧៧% | +២០% |
| – ពន្ធលើប្រាក់ចំណេញ | ៩៧% | +២១% |
| – ពន្ធលើឈ្នួលផ្ទះ–ដី | ៨៧% | +១៦% |
| – អាករលើផលរបរ | ៥០% | -១៥% |
| – អាករលើតម្លៃបន្ថែម | ៦៦% | -១១% |
| –អាករពិសេស | ៩៥% | +២៣% |
| –ផ្សេងៗ | ១០៣% | +៤២% |
| –ពន្ធថវិកាខេត្តរាជធានី | ១៦១% | +៤៧% |
| ✓**ចំណូលសារពើពន្ធផ្សេងៗ** | ១១៥% | +៨% |
| –ចំណូលពីកាស៊ីណូ | ៩៦% | +២% |
| –ចំណូលពីអាជ្ញាបណ្ណក្នុងស្រុក | ១៨២% | -១៦% |
| –ចំណូលពីកម្រៃការគ្រប់គ្រង និងទិដ្ឋាកានាំចេញ | ១២៦% | +១៥% |

| មុខចំណូល | អនុវត្ត គម្រោង | %∆ធៀបនឹង ឆ្នាំ២០១០ |
|---|---|---|
| **ចំណូលមិនមែនសារពើពន្ធ** | ៨៨% | -១៤% |
| ✓នេសាទ | ៧៤% | -១១% |
| ✓ រុក្ខាប្រមាញ់ | ១៦០% | +៣% |
| ✓សម្បទានរ៉ែ | ១១៣% | -៩២% |
| ✓អាកាសចរណ៍ស៊ីវិល | ១១២% | +១១% |
| ✓ ផលទុនទេសចរណ៍ | ៧៥% | +៣០% |
| ✓ប្រៃសណីយ៍ និងទូរគមនាគមន៍ | ១១១% | +២៧% |
| ✓អាករស្ថានទូត លិខិតឆ្លងដែន និងទិដ្ឋាការ | ១២២% | +៣៩% |
| ✓ ត្រួតពិនិត្យគុណភាពផលិតផល | ១៤៥% | +១៤% |
| ✓ ជួលរោងចក្រ សហគ្រាស | ៨៨% | ០ |
| ✓ឯកជនភាវូបនីយកម្ម | ៣៤% | -៥១% |
| ✓ ការលក់អចលនកម្ម | ៨៧% | -៣៩% |

•**ចំណាយថវិកាជាតិ**ក្នុងឆ្នាំ២០១១ អនុវត្តបាន ៦ ៦១៦ ពាន់លានរៀល ស្មើនឹង ៧៦% នៃគម្រោង ក្នុងនោះ ចំណាយចរន្ត ៥ ៣២៧ ពាន់លានរៀលស្មើនឹង ១១១% នៃគម្រោង និងចំណាយមូលធន ១ ២៨៨ ពាន់លានរៀលស្មើនឹង ៣៣% នៃគម្រោង។

•បើប្រៀបធៀបឆ្នាំ២០១១/២០១០ យើងសង្កេតឃើញថា៖

▪ ចំណាយថវិកាជាតិកើនឡើង ១១%

▪ ចំណាយចរន្តកើនឡើង ១២%

▪ ចំណាយមូលធនកើនឡើង ៩%

• ជាលទ្ធផល **តុល្យភាពថវិកាជាតិ** នាឆ្នាំ២០១១ មានឱនភាពចំនួន ១៨១ ពាន់លានរៀល។ តារាងទិន្នន័យថវិកាជាតិ ពុំមានតួលេខបង្ហាញអំពីការធ្វើហិរញ្ញប្បទានឱនភាពថវិកាទេ។

## ៣) ស្ថានភាពរូបិយវត្ថុនិងអត្រាការប្រាក់

•សេដ្ឋកិច្ចដុល្លាររូបនីយកម្មនៃកម្ពុជាក្នុងឆ្នាំ២០១១ មានសូចនាកររូបិយវត្ថុដូចខាងក្រោម៖

▪ រូបិយវត្ថុ *M1* មាន ១៧%នៃ *M2* ក្នុងនោះ

– រូបិយវត្ថុក្រៅធនាគារ ១៦% នៃ *M2*

– ប្រាក់បញ្ញើចរន្ត មាន ១% នៃ *M2*។

▪ រូបិយវត្ថុផ្សេងៗមាន៨៣% នៃ*M2* (២០១០= ៨៣%) ក្នុងនោះ៖

– ប្រាក់បញ្ញើជារូបិយបណ្ណ ៨១% នៃ *M2*

–ប្រាក់បញ្ញើមានកាលកំណត់និងសន្សំ មាន ប្រហែល ២% នៃ *M2*។




• ជារួម សមាសធាតុរូបិយវត្ថុនៃសេដ្ឋកិច្ចកម្ពុជា មិនមានការប្រែប្រួលគួរឲ្យចាប់អារម្មណ៍ទេ ធៀបនឹងឆ្នាំមុនៗ។ យ៉ាងណាក្តី រូបិយវត្ថុ *M2* មានការកើនឡើងជាលំដាប់។ ក្នុងឆ្នាំ២០១១ *M2* មានចំនួនប្រហែល ៤៦% នៃផសសប៉ុន្តែបមាណភាគ *M1* ក្នុងផសស មានត្រឹមតែ ៧,៧% ប៉ុណ្ណោះ។ ក្រាហ្វខាងស្តាំជាការប្រៀបធៀបបមាណភាគ *M2*/**ផសស** សម្រាប់ប្រទេសកម្ពុជា ថៃ និង វៀតណាម។




**ប្រភព : តួលេខប្រទេសថៃ និងវៀតណាមបានពី** Key indicators for Asia and the Pacific 2011: ADB

• នាចុងឆ្នាំ២០១១ M2 មានចំនួន ២៣ ៦៥៥ ពាន់លានរៀល កើនឡើង ២១% បើធៀបនឹងឆ្នាំ២០១០។ ការកើនឡើងនៃ M2 នេះបណ្តាលមកពីការកើនឡើងនៃរូបិយវត្ថុក្រៅធនាគារ ២២% ប្រាក់បញ្ញើចរន្ត ៥១% ប្រាក់បញ្ញើមានកាលកំណត់និងសន្សំ ៣៦% និង ប្រាក់បញ្ញើជារូបិយបណ្ណ ២១%។

• ទុនបំរុងជារូបិយប័ណ្ណបរទេសសុទ្ធ មានចំនួន ២ ៩២៦ លានដុល្លារ កើនឡើង ១៥% បើធៀបនឹងឆ្នាំ២០១០។

•***ប្រាក់បញ្ញើរបស់ធនាគារពាណិជ្ជនៅធនាគារជាតិនៃកម្ពុជា*** មាន ៧ ០៤៨ ពាន់លានរៀលថយចុះ ៤% បើធៀបនឹងឆ្នាំមុន។

• ការផ្តល់ឥណទានដោយធនាគារពាណិជ្ជមាន ១៧ ៦៦៨ ពាន់លានរៀល បើធៀបនឹងឆ្នាំមុនកើនឡើង ៣៤%។

• ការផ្តល់ឥណទានដោយគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ មានចំនួន ២ ៥៩១ ពាន់លានរៀល កើនឡើង ៥០% ។

•**អត្រាការប្រាក់ប្រចាំឆ្នាំ៖**

| *ប្រភេទអត្រាការប្រាក់* | *អត្រាឆ្នាំ២០១១* | *អត្រាឆ្នាំ២០១០* | %∆២០១១/២០១០ |
|---|---|---|---|
| បញ្ញើជារៀលនៅធនាគារពាណិជ្ជ | ៦,២១% | ៦,៥៩% | –៦% |
| កម្ចីជារៀលនៅធនាគារពាណិជ្ជ | ១៦,៩១% | ២២,៧៨% | –២៦% |
| បញ្ញើជាដុល្លារនៅធនាគារពាណិជ្ជ | ៤,២៨% | ៤,៤១% | –៣% |
| កម្ចីជាដុល្លារនៅធនាគារពាណិជ្ជ | ១៥,១៤% | ១៧,២១% | –១២% |

## ៤) ស្ថានភាពកសិកម្ម ឧស្សាហកម្ម សេវាកម្ម និងវប្បធម៌

### •កសិកម្ម៖

▪ ផលិតផលស្រូវនៅកម្ពុជាមានការកើនឡើងជាលំដាប់។ ក្នុងឆ្នាំ២០១១ ផលិតផលស្រូវ មានបរិមាណ ៨ ៤១៧ ពាន់តោន កើនឡើង ២% បើធៀបនឹងឆ្នាំ២០១០ ដែលមានបរិមាណ ៨ ២៤៩ ពាន់តោន។ ក្នុងរយៈពេល ៥ឆ្នាំចុងក្រោយ (២០០៧-២០១១) ផលិតផលស្រូវកើនជាមធ្យម ៦% ក្នុងមួយឆ្នាំ។

▪ ផលិតផលស្រូវកើនឡើង ដោយសារកំណើននៃផ្ទៃដីដាំដុះ និងទិន្នផលស្រូវ។ ក្នុងឆ្នាំ២០១១ ការដាំស្រូវទាំងពីររដូវ បានធ្វើលើផ្ទៃដីចំនួន ២ ៩១២ ពាន់ហិកតា លើសឆ្នាំ២០១០ ចំនួន ១១៦ ពាន់ហិកតា។




ចំណែកឯទិន្នផលស្រូវជាមធ្យម ទាំងស្រូវប្រាំងទាំងស្រូវវស្សាក្នុងឆ្នាំ២០១១ ស្មើនឹង ៣,១១ តោន/១ហិកតា។ តួលេខទិន្នផលស្រូវ បានមកពីផលធៀបនៃផលិតផលសរុប និងផ្ទៃដីប្រមូលផល។

▪ ផលិតផលកៅស៊ូ ជាទូទៅមានការកើនជារៀងរាល់ឆ្នាំ។ ក្នុងឆ្នាំ២០១១ ផលិតផលកៅស៊ូមានចំនួន ៥១,៣ ពាន់តោន កើនឡើង ២១,៤% ធៀបនឹងឆ្នាំ២០១០។ ក្នុងឆ្នាំ២០១១ ផ្ទៃដីចៀរជ័រមាន ៤៥,២ ពាន់ហិកតា និងផ្ទៃដីដាំដុះសរុបមាន ២១៣,១ ពាន់ហិកតា។

▪ ផលិតកម្មនេសាទឆ្នាំ២០១១ មានចំនួន **៥៨៦ ពាន់តោន** កើនឡើង ៩% ធៀបនឹងឆ្នាំ២០១០។

### •ឧស្សាហកម្ម៖

▪ថាមពលអគ្គិសនីផ្គត់ផ្គង់ដោយអគ្គិសនីកម្ពុជាមានចំនួន ២៥៩៥ លានគីឡូវ៉ាត់ម៉ោង កើនឡើង ១៦% ។ ក្នុងនោះ វារីអគ្គិសនីមានចំនួន ៥១ លានគីឡូវ៉ាត់ម៉ោង កើនឡើង ៦៦%។

▪ផលិតកម្មវាយនភណ្ឌនិងស្បែកជើងសម្រេចបាន ៣៩៦៤ លានដុល្លារ កើនឡើង ២៧%។ ជាទូទៅ ផលិតកម្មវាយនភណ្ឌនិងស្បែកជើងមានទំហំធំនៅឆមាសទី២។

▪ទឹកស្អាតផ្គត់ផ្គង់ដោយរដ្ឋាករទឹក មានចំនួន ១៣៨លានម៣ កើនឡើង ៧% ។

▪ **ការចុះបញ្ជី ការបើកថ្មី និងការបន្ត រោងចក្រ សហគ្រាស នៅក្រសួងឧស្សាហកម្ម៖**

| *ប្រភេទ* | *ចំនួន: ២០១១* | *ចំនួន: ២០១០* | %∆ |
|---|---|---|---|
| រោងចក្រថ្មី ដែលបានចុះបញ្ជី | ១០៨ | ៧៤ | +៤៦% |
| ឧស្សាហកម្មធុនតូច និងសិប្បកម្ម (បើកថ្មី) | ២៥៣ | ១១៤ | +១២២% |
| ឧស្សាហកម្មធុនតូច និងសិប្បកម្ម (បន្ត) | ២១៣ | ១៨១ | +១៨% |

▪**សំណង់ (ការអនុញ្ញាត)៖**

| *ប្រភេទសំណង់* | ពាន់ម២:២០១១ | ពាន់ម២:២០១០ | % ∆ |
|---|---|---|---|
| លំនៅឋាន | ២០៥១ | ១ ៤៧០ | +៤០% |
| ឧស្សាហកម្ម | ១ ៣២៤ | ៦១៥ | +១១៥% |
| ពាណិជ្ជកម្ម | ៣៣៤ | ១៤៥ | +១៣១% |
| ទេសចរណ៍ | ១ ២៨៧ | ១៧៥ | +៦៣៥% |
| ... | | | |
| អនុញ្ញាតសរុប | ៥ ២៥៨ | ៣ ២៨៧ | +៦០% |

▪ការអនុញ្ញាតឲ្យសាងសង់ឆ្នាំ២០១១ មានទឹកប្រាក់ស្មើនឹង ១៧៣៤ លានដុល្លារ កើនឡើង ១០៦% ធៀបនឹងឆ្នាំ ២០១០។ ក្នុងការអនុញ្ញាតឆ្នាំ២០១១នេះ សំណង់ដែលពេញនិយមមាន លំនៅឋាន (៣៩% នៃផ្ទៃក្រឡាសរុប) ឧស្សាហកម្ម (២៥% នៃផ្ទៃក្រឡាសរុប) និងទេសចរណ៍ (២៤% នៃផ្ទៃក្រឡាសរុប)។

**▪ការងារ៖**

| ប្រភេទ | ២០១១ (នាក់) | ២០១០ (នាក់) | %∆ |
|---|---|---|---|
| ការដាក់ពាក្យរកការងារទៅក្រៅប្រទេស | ៣៣១៦៥ | ៤១៩៥៣ | -២០% |
| អ្នកទទួលបានការងារតាមរយៈក្រសួងការងារ និងក្រុមហ៊ុន | ៣៩០៧៣ | ៧២១១៨ | -៤៦% |
| អ្នកទទួលបានការងារក្នុងប្រទេស | ១៧៨១១ | ៤៤៤៥១ | -៦០% |
| អ្នកទទួលបានការងារក្រៅប្រទេស | ២១ ២៦២ | ២៧៦៦៧ | -២៣% |

**▪វិនិយោគ៖** គម្រោងវិនិយោគអនុញ្ញាតដោយ គ.វ.ក/គ.អ.ក ក្នុងឆ្នាំ២០១១ (ថ្មី និងពង្រីក) មានចំនួន ១៦១ គម្រោង។ ជាទុនវិនិយោគមានទឹកប្រាក់ ៧ ៣១១ លានដុល្លារ និងអាចផ្តល់ការងារបាន ២២៩ ពាន់នាក់។

| ប្រភេទ | ២០១១ | ២០១០ | %∆ |
|---|---|---|---|
| **អនុញ្ញាតសរុប (លានដុល្លារ)** | ៧ ៣១១ | ២ ៩៤៤ | +១៤៨% |
| វិស័យកសិកម្មនិងកសិឧស្សាហកម្ម | ៨០៨ | ៥៩៩ | +៣៥% |
| វិស័យឧស្សាហកម្ម | ២ ៨៧៦ | ៤៧៨ | +៥០២% |
| វិស័យទេសចរណ៍ | ៦៦៧ | ១៣២ | +៤០៥% |
| វិស័យហេដ្ឋារចនាសម្ព័ន្ធនិងផ្សេងៗ | ២ ៩៦០ | ១ ៧៣៥ | +៧១% |
| **ចំនួនគម្រោងថ្មីនិងពង្រីក (ចំនួន)** | ១៦១ | ១២០ | +៣៤% |
| **ចំនួនពលករ (ពាន់នាក់)** | ២២៩ | ១៤៩ | +៥៤% |

***▪សេវាកម្មនិងទេសចរណ៍៖***

**➢ការចុះបញ្ជីនិងលុបចេញពីបញ្ជី នៅក្រសួងពាណិជ្ជកម្ម**

| ប្រភេទ | ២០១១ (ចំនួន) | ២០១០(ចំនួន) | %∆ |
|---|---|---|---|
| ក្រុមហ៊ុនដែលបានចុះបញ្ជីពាណិជ្ជកម្ម | ៣ ០៩១ | ២ ៥៧២ | +២០% |
| ក្រុមហ៊ុនត្រូវបានលុបចេញពីបញ្ជីពាណិជ្ជកម្ម | ៣៨ | ៣២ | +១៩% |
| ក្រុមហ៊ុនដែលបានចុះបញ្ជីបង់ពន្ធដារតាមរបបពិត | ៣ ១២៤ | ២ ៥៩០ | +២១% |

**➢ទំនិញឆ្លងកាត់កំពង់ផែ** (សរុប៦កំពង់ផែ)មានចំនួន ៤៣៤៦ ពាន់តោនកើនឡើង១១%។ ក្នុងនោះ៖

| ប្រភេទ | ២០១១ (ពាន់តោន) | ២០១០ (ពាន់តោន) | %∆ |
|---|---|---|---|
| ផែភ្នំពេញ | ១ ៥២២ | ១ ២៥៣ | +២១% |
| ផែកំពង់សោម | ២ ៣៧៨ | ២ ១៥៤ | +១០% |
| ផែស្រែអំបិល និងកោះកុង | ៥៤៩ | ២៥១ | +១១៩% |
| ផែឧកញ៉ាម៉ុង | ១៨៦ | ២៣៤ | -២០% |

### ➢អ្នកដំណើរតាមផ្លូវអាកាស និងទេសចរណ៍

| *ប្រភេទ* | ២០១១ (ពាន់នាក់) | ២០១០ (ពាន់នាក់) | %Δ |
|---|---|---|---|
| ភ្ញៀវអន្តរជាតិចូលទស្សនាសារមន្ទីរជាតិ | ៨៩ | ៨២ | +៩% |
| អ្នកដំណើរតាមផ្លូវអាកាស (ក្នុងស្រុក) | ១៤៤ | ១៣៦ | +៦% |
| អ្នកដំណើរតាមផ្លូវអាកាស (អន្តរជាតិ) | ៣ ៤២៥ | ៣ ០៨៣ | +១៣% |
| អ្នកទេសចរជាតិចេញក្រៅប្រទេស | ៧០៩ | ៥០៥ | +៤១% |
| អ្នកទេសចរអន្តរជាតិមកកម្ពុជា | ២ ៨៨២ | ២ ៥០៨ | +១៥% |
| ✓តាមផ្លូវអាកាស | ១ ៤៧៩ | ១ ៣០៤ | +១៣% |
| ✓ តាមផ្លូវគោក និងទឹក | ១ ៤០២ | ១ ១៩៨ | +២១% |

## ៥) ស្ថានភាពជញ្ជីងពាណិជ្ជកម្ម

•ជារួម កម្ពុជាមានឱនភាពជញ្ជីងពាណិជ្ជកម្មជាប្រចាំ ទោះបីការនាំចេញកន្លងមកមាននិន្នាការកើនឡើងក្តី។ ឱនភាពនេះ មួយផ្នែកធំត្រូវបានទូទាត់ដោយលំហូរវិនិយោគបរទេសមកក្នុងសេដ្ឋកិច្ចកម្ពុជា។

• យោងតាមការកត់ត្រារបស់អគ្គនាយកដ្ឋានគយ និងរដ្ឋាករ **ការនាំចូល**ក្នុងឆ្នាំ២០១១ មានចំនួន ២៥ ៥៤៩ ពាន់លានរៀល កើនឡើង ២៧% បើធៀបនឹងឆ្នាំ២០១០។ក្នុងនោះ៖

| មានការថយចុះ | មានការកើនឡើង | |
|---|---|---|
| ប្រេងកាត -៣១% | ស៊ាំង +៤% | ស្រូវសាលី +១២% |
| ប្រេងខ្មៅ -៦% | ម៉ាស៊ូត +៦% | អង្ករ +១៨% |
| ម៉ូតូ -១៣% | ឧស្ម័ន +១១% | ជីនិងថ្នាំកសិកម្ម +៤០% |
| ផ្លែឈើនិងបន្លែ -២៧% | អគ្គិសនីនាំចូល +១៩% | ភេសជ្ជៈ +៩៥% |
| បារី -២០% | ដែកសំណង់ +១% | ប្រេងឆា +៣៦% |
| ស្ករស -៤៥% | ស៊ីម៉ង់ +៦% | ការនាំចូលក្នុងក្របខ័ណ្ឌច្បាប់វិនិយោគ +២៤% |
| ប៊ីចេង -៧០% | គ្រឿងអេឡិចត្រូនិច +១៥% | |
| | វថយន្តសរុប (ជាសាច់ប្រាក់) +២២% | |
| | ត្រាក់ទ័រនិងគោយន្ត +១៤% | |

•**ការនាំចេញ**ឆ្នាំ២០១១ មានចំនួន ២០ ០១៤ ពាន់លានរៀលកើនឡើង ២៧% ធៀបនឹងឆ្នាំ២០១០។ក្នុងនោះ៖

| *ទំនិញ* | %Δ ធៀបនឹងឆមាស១ -២០១០ | *ទំនិញ* | %Δ ធៀបនឹងឆមាស១ -២០១០ |
|---|---|---|---|
| ផលិតផលឈើកែច្នៃ | +៣៧% | អង្ករ | +២៤៤% |
| វាយនភណ្ឌនិងស្បែកជើង | +២៥% | ផលិតផលនេសាទ | -១៤% |
| កៅស៊ូ | +៦៣% | | |

*•ក្នុងឆ្នាំ២០១១ ឱនភាពជញ្ជីងពាណិជ្ជកម្មមាន ៥.៥៣៥ ពាន់លានរៀលស្មើនឹង ១ ៣៧០លានដុល្លារស.រ.អា ដែលមានទំហំ ២៨% នៃតម្លៃនាំចេញ។ ឱនភាពជញ្ជីងពាណិជ្ជកម្មតែងតែមានទំហំធំក្នុងឆមាសទី១។*

## ៦) បម្រែបម្រួលគួរឲ្យចាប់អារម្មណ៍

ក្នុងឆ្នាំ២០១១ នេះ សូចនាករសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ នៃព្រះរាជាណាចក្រកម្ពុជា បង្ហាញបម្រែបម្រួលគួរឲ្យចាប់អារម្មណ៍ដូចខាងក្រោម៖

| សូចនាករ | បម្រែបម្រួលធៀបនឹងឆ្នាំ២០១០ | ផ្សេងៗ |
|---|---|---|
| ១. ថ្លៃសាច់ជ្រូក | +១៦% | ប្រទេសកម្ពុជានាពេលបច្ចុប្បន្ន មានការពឹងផ្អែកខ្លាំងលើការនាំចូលជ្រូកពីបរទេស ឯការចិញ្ចឹមក្នុងស្រុកស្ថិតក្នុងស្ថានភាពទាប។ |
| ២. ថ្លៃផ្លែឈើ | +១០% | — |
| ៣. ថ្លៃឧស្ម័ន | +១៦% | — |
| ៤. ថ្លៃប្រេងសាំង | +១៦% | — |
| ៥. ថ្លៃប្រេងម៉ាស៊ូត | +២២% | — |
| ៦. អាករលើផលរបរ | -១៥% | ជាមុខចំណូលពន្ធដារ |
| ៧. អាករលើតម្លៃបន្ថែម | -១១% | ជាមុខចំណូលពន្ធដារ |
| ៨. ចំណូលពីអាជ្ញាបណ្ណក្នុងស្រុក | -១៦% | ជាមុខចំណូលសារពើពន្ធផ្សេងៗ |
| ៩. ចំណូលមិនមែនសារពើពន្ធ | -១៤% | — |
| ១០. រូបិយវត្ថុក្រៅធនាគារ | +២២% | ជាសាច់ប្រាក់រៀលនៅក្រៅធនាគារ |
| ១១. អត្រាការប្រាក់កម្ចីជាដុល្លារនៅធនាគារពាណិជ្ជ | -១២% | — |
| ១២. អត្រាការប្រាក់កម្ចីជារៀលនៅធនាគារពាណិជ្ជ | -២៦% | — |
| ១៣. ការនាំចេញផលិតផលនេសាទ | -១៤% | មានការបិទឡូត៍នេសាទ |

## ៧) ស្មារតីអង្គប្រជុំ និងការសន្និដ្ឋាន

***អង្គប្រជុំបានពិភាក្សាបញ្ហាសំខាន់ គួរឲ្យចាប់អារម្មណ៍ដូចខាងក្រោម៖***

១) ថ្លៃម្ហូបអាហារនឹងបន្តកើនឡើងក្នុងសកលលោក។

២) នៅប្រទេសកម្ពុជា សាច់ជាក្រុមម្ហូបអាហារដែលមានការរួមចំណែកធំលើកម្រិតថ្លៃសរុប ជាពិសេសសាច់ជ្រូកមានការឡើងថ្លៃខ្ពស់បំផុតនៅក្នុងក្រុមម្ហូបអាហារ។

៣) ការឡើងថ្លៃប្រេងឥន្ធនៈ និងកង្វះខាតការគ្រប់គ្រងថ្លៃ បានធ្វើឲ្យមានកំណើនថ្លៃដឹកជញ្ជូន និងថ្លៃដើមផលិត។

៤) កង្វះទុន កង្វះបច្ចេកទេស និងកង្វះសង្វាក់ផលិតកម្មនៃទំនិញអន្តរការី ដូចជា ចំណីសត្វ បង្ករឲ្យមានភាពទន់ខ្សោយនៃការផ្គត់ផ្គង់ក្នុងស្រុក។

៥) ក្នុងឆ្នាំ២០១១ ជនជាតិបរទេសបានទិញអគារសំណង់ដែលបានសាងសង់ចំនួន ៦៧០ ឯកតា។

៦) យោងតាមការកត់ត្រារបស់អគ្គនាយកដ្ឋានគយ និងរដ្ឋាករ ការនាំចេញអង្ករនៅក្នុងឆ្នាំ២០១១ មានចំនួន ១៧៦ ពាន់តោន មានការកើនឡើងខ្ពស់បើធៀបនឹងឆ្នាំ២០១០។ ប៉ុន្តែបើប្រៀបធៀបនឹងផែនការនាំចេញអង្ករឆ្នាំ២០១៥ បរិមាណនេះមានប្រហែល ១៨% នៃផែនការប៉ុណ្ណោះ។

***សេចក្តីសន្និដ្ឋាន៖***

១) ដើម្បីជម្រុញការចិញ្ចឹមជ្រូក រាជរដ្ឋាភិបាលគួរលើកគោលនយោបាយគាំពារ រួមជាមួយការលើកទឹកចិត្តដល់អ្នកវិនិយោគក្នុងវិស័យនេះ និងវិធានការផ្សេងៗទៀត។

២) វិស័យធនាគារបង្ហាញសញ្ញាវិជ្ជមានមួយចំនួនដូចជា មានកំណើនការផ្គត់ផ្គង់សាច់ប្រាក់រៀល និងអត្រាការប្រាក់មានការថយចុះខ្លះ។ ការចាប់ផ្តើមនៃទីផ្សារមូលបត្រ នឹងជួយកៀរគរមូលធនពីអ្នកសន្សំទៅឲ្យអ្នកខ្ចីយ៉ាងមានប្រសិទ្ធភាព។

៣) នៅតែមានការនាំចេញស្រូវយ៉ាងច្រើនទៅប្រទេសជិតខាង។ ដូច្នេះគួរបង្កើនការជម្រុញការប្រមូលទិញស្រូវ ដោយផ្តល់ថ្លៃដែលអាចប្រកួតប្រជែង និងបង្កើនចំនួនម៉ាស៊ីនកិនស្រូវឲ្យបានគ្រប់គ្រាន់។

# សកម្មភាពផ្សេងទៀតរបស់ឯកឧត្តម យឹម ណុលឡា ទេសរដ្ឋមន្ត្រីទទួលបន្ទុកបេសកកម្មពិសេស ប្រធានក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ ប្រចាំខែកុម្ភៈ ឆ្នាំ២០១២

| ល.រ | កាលបរិច្ឆេទ | សកម្មភាព |
|---|---|---|
| ១ | ០១/០២/១២<br>ម៉ោង ០៩:០០ នាទី | ជួបប្រជុំពិភាក្សាការងារជាមួយអ្នកវិនិយោគម៉ាឡេស៊ី នៅទីស្តីការគណៈរដ្ឋមន្ត្រី។ |
| ២ | ០១/០២/១២<br>ម៉ោង ១៥:០០ នាទី | ដឹកនាំកិច្ចប្រជុំគណៈកម្មការបច្ចេកទេស ដើម្បីសម្របសម្រួលការអនុវត្តគម្រោងវិនិយោគសាងសង់អគារសារមន្ទីរសព្វទស្សន៍ ( Grand Panorama Museum ) នៅទីស្តីការគណៈរដ្ឋមន្ត្រី។ |
| ៣ | ០១/០២/១២<br>ម៉ោង ១៦:០០ នាទី | ចូលរួមជាកិត្តិយសក្នុងពិធីចុះហត្ថលេខាលើអនុស្សរណៈ នៃការយោគយល់គ្នាជាមួយស្ថានទូតនៃសាធារណរដ្ឋឥណ្ឌា ប្រចាំនៅព្រះរាជាណាចក្រកម្ពុជា ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ ឯកឧត្តម បណ្ឌិតសភាចារ្យ **សុខ អាន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី នៅទីស្តីការគណៈ-រដ្ឋមន្ត្រី។ |
| ៤ | ០១/០២/១២<br>ម៉ោង ១៧ : ៣០ នាទី | ជួបប្រជុំពិភាក្សាការងារជាមួយ ឯកឧត្តម **សយ សុខា** ឯកឧត្តម **តឹករ៉េត សំរេច** និងឯកឧត្តម **ជា វ៉ាន់ដេត** អំពីការងារពាក់ព័ន្ធនឹង SCA នៅទីស្តីការគណៈរដ្ឋមន្ត្រី។ |
| ៥ | ០២/០២/១២<br>ម៉ោង ០៩:៣០ នាទី | ចូលរួមជាសមាជិកក្នុងកិច្ចប្រជុំត្រួតពិនិត្យជាចុងក្រោយ សម្រាប់ប្រជុំពេញអង្គគណៈរដ្ឋមន្ត្រី ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ ឯកឧត្តម បណ្ឌិតសភាចារ្យ **សុខ អាន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី ដើម្បីពិនិត្យ និងពិភាក្សាលើ៖<br>១-សេចក្តីព្រាងរបាយការណ៍ពាក់កណ្តាលអាណត្តិឆ្នាំ២០១១ ស្តីពីការអនុវត្តផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិបច្ចុប្បន្នកម្ម ២០០៩-២០១៣។<br>២-សេចក្តីព្រាងអនុក្រឹត្យស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់អគ្គលេខាធិការដ្ឋាននៃគណៈកម្មាធិការជាតិវាយតម្លៃទីក្រុងស្អាត។<br>៣-សេចក្តីព្រាងព្រះរាជក្រឹត្យស្តីពីការបង្កើតបញ្ញត្តិករទូរគមនាគមន៍កម្ពុជា។<br>៤-បញ្ហាផ្សេងៗ ។<br>នៅទីស្តីការគណៈរដ្ឋមន្ត្រី។ |
| ៦ | ០២/០២/១២<br>ម៉ោង ១៦:០០ នាទី | ចូលរួមជាកិត្តិយសក្នុងពិធីចុះហត្ថលេខា ក្នុងនាមតំណាងរាជរដ្ឋាភិបាល លើគម្រោងជំនួយរដ្ឋាភិបាលអាល្លឺម៉ង់ សម្រាប់គាំទ្រការដោះមីនរបស់ស៊ីម៉ាក់ សម្រាប់ឆ្នាំ២០១២ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ឯកឧត្តម បណ្ឌិតសភាចារ្យ **សុខ អាន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី នៅទីស្តីការគណៈរដ្ឋមន្ត្រី។ |
| ៧ | ០៣/០២/១២<br>ម៉ោង ០៩:៣០ នាទី | ចូលរួមជាកិត្តិយសអម ឯកឧត្តម បណ្ឌិតសភាចារ្យ **សុខ អាន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី ដើម្បីចូលរួមស្តាប់សវនាការប្រកាសសាលដីការបស់អង្គជំនុំជម្រះតុលាការកំពូលលើសំណុំរឿង ០០១ ប្រឆាំងនឹង **កាំង ហ្គេកអ៊ាវ** ហៅ ឌុច នៅសាលសវនាការរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា។ |

# សកម្មភាពផ្សេងៗទៀតរបស់ឯកឧត្តម យឹម ណុលឡា ទេសរដ្ឋមន្ត្រីទទួលបន្ទុកបេសកកម្មពិសេស ប្រធានក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ ប្រចាំខែកុម្ភៈ ឆ្នាំ២០១២ (ត)

| ល.រ | កាលបរិច្ឆេទ | សកម្មភាព |
|---|---|---|
| ៨ | ០៦/០២/១២<br>ម៉ោង ១៦:៣០ នាទី | ប្រជុំការងារជាមួយ លោក **ហេង គឹមលេង** ប្រធាននាយកដ្ឋានទ្រទ្រង់បច្ចេកទេស និងអន្តរវិស័យអាជ្ញាធរអប្សរា ពាក់ព័ន្ធនឹងគម្រោងសាងសង់ផ្លូវ T1 ក្នុងខេត្តសៀមរាប នៅបន្ទប់ ឯកឧត្តម ប្រធាន ECOSOCC នៃទីស្តីការនាយករដ្ឋមន្ត្រី។ |
| ៩ | ០៩/០២/១២<br>ម៉ោង ០៩:០០ នាទី | ជាអធិបតីក្នុងពិធីចុះហត្ថលេខាលើកិច្ចសន្យាគូរប្លង់អគារមជ្ឈមណ្ឌលព័ត៌មាន និងបច្ចេកវិទ្យានៃទីស្តីការគណៈរដ្ឋមន្ត្រី ជាមួយស្ថានទូតសាធារណរដ្ឋប្រជាមានិតចិនប្រចាំកម្ពុជា នៅទីស្តីការគណៈរដ្ឋមន្ត្រី។ |
| ១០ | ១០/០២/១២<br>ម៉ោង ០៨:៣០ នាទី | ចូលរួមក្នុងអង្គប្រជុំពេញអង្គគណៈរដ្ឋមន្ត្រី ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ដើម្បីពិភាក្សាលើរបៀបវារៈដូចខាងក្រោម៖<br>១-សេចក្តីព្រាងព្រះរាជក្រឹត្យស្តីពីការបង្កើតបញ្ញត្តិករទូរគមនាគមន៍កម្ពុជា។<br>២-ឯកសារយុទ្ធសាស្ត្រស្តីពីការគ្រប់គ្រងបំណុលសាធារណៈ២០១១-២០១៨។<br>៣-សេចក្តីព្រាងអនុក្រឹត្យស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់អគ្គលេខាធិការដ្ឋាន នៃគណៈកម្មាធិការជាតិវាយតម្លៃទីក្រុងស្អាត។<br>៤-បញ្ហាផ្សេងៗ ។<br>នៅទីស្តីការនាយករដ្ឋមន្ត្រី។ |
| ១១ | ១៣/០២/១២<br>ម៉ោង ១៦:៣០ នាទី | ចូលរួមជាកិត្តិយសក្នុងពិធីចុះហត្ថលេខាលើកិច្ចព្រមព្រៀង រវាងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា និងអង្គការយូណេស្កូ ស្តីពីការជួសជុលប្រាសាទបាយ័ន ដំណាក់កាលទី៤ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ ឯកឧត្តម បណ្ឌិតសភាចារ្យ **សុខ អាន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី នៅទីស្តីការគណៈរដ្ឋមន្ត្រី។ |
| ១២ | ១៤/០២/១២<br>ម៉ោង ០៨:០០ នាទី | ចូលរួមជាកិត្តិយសក្នុងពិធីបើកការដ្ឋានសាងសង់ពង្រីកកំណាត់ផ្លូវជាតិលេខ ៦ ប្រវែង ៤០.៥០០ គ.ម ពីគីឡូម៉ែត្រលេខ ៤ ដល់ថ្នល់កែង ក្រោមកម្ចីឥណទានពីរដ្ឋាភិបាលនៃសាធារណរដ្ឋប្រជាមានិតចិន ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា និងលោកជំទាវកិត្តិព្រឹទ្ធបណ្ឌិត នៅភូមិខ្វរ សង្កាត់ព្រែកលៀប ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ។ |
| ១៣ | ១៦/០២/១២ ម៉ោង ០៧:៤៥ នាទី | ចូលរួមជាកិត្តិយសក្នុងពិធីផ្ទេរ-ប្រគល់ជំនួយសម្ភារៈបច្ចេកទេសដំណាក់កាលទី៦ របស់រដ្ឋាភិបាលជប៉ុន ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ ឯកឧត្តម បណ្ឌិតសភាចារ្យ **សុខ អាន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី នៅទីបញ្ជាការដ្ឋានសីុម៉ាក់ ខេត្តសៀមរាប។ |
| ១៤ | ២០/០២/១២<br>ម៉ោង ០៧:៣០នាទី | ចូលរួមជាកិត្តិយសក្នុងកិច្ចប្រជុំបូកសរុបលទ្ធផលការងារប្រចាំឆ្នាំ២០១១ និងលើកទិសដៅការងារឆ្នាំ២០១២ របស់ក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីស្ត្រី ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា នៅទីស្តីការនាយករដ្ឋមន្ត្រី។ |

## សកម្មភាពដទៃទៀតរបស់ឯកឧត្តម យឹម ណុលឡា ទេសរដ្ឋមន្ត្រីទទួលបន្ទុកបេសកកម្មពិសេស ប្រធានក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ ប្រចាំខែកុម្ភៈ ឆ្នាំ២០១២ (តចប់)

| ល.រ | កាលបរិច្ឆេទ | សកម្មភាព |
|---|---|---|
| ១៥ | **២១/០២/១២** ម៉ោង ១៤:៣០ នាទី | ចូលរួមជាកិត្តិយសក្នុងពិធីបិទសន្និបាតបូកសរុបការងារឆ្នាំ២០១១ និងទិសដៅឆ្នាំ២០១២ របស់ក្រសួងអភិវឌ្ឍន៍ជនបទ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា និងលោកជំទាវកិត្តិព្រឹទ្ធបណ្ឌិត នៅសាលសន្និសីទចតុមុខ។ |
| ១៦ | **២២/០២/១២** ម៉ោង ០៩:៣០ នាទី | ចូលរួមជាមួយ ឯកឧត្តម បណ្ឌិតសភាចារ្យ **សុខ អាន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី ក្នុងការអនុញ្ញាតឲ្យឯកឧត្តម Hong Ki Chol ឯកអគ្គរដ្ឋទូតថ្មី នៃសាធារណរដ្ឋប្រជាមានិតប្រជាធិបតេយ្យកូរ៉េ ប្រចាំនៅព្រះរាជាណាចក្រកម្ពុជា ចូលជួបសម្តែងការគួសម នៅទីស្តីការគណៈរដ្ឋមន្ត្រី។ |
| ១៧ | **២៣/០២/១២** ម៉ោង ០៩:០០ នាទី | ដឹកនាំកិច្ចប្រជុំគណៈកម្មការបច្ចេកទេស ដើម្បីសម្របសម្រួលការងារអនុវត្តគម្រោងវិនិយោគសាងសង់អគារសារមន្ទីរសព្វទស្សន៍ (Grand Panorama Museum) នៅទីស្តីការគណៈរដ្ឋមន្ត្រី។ |
| ១៨ | **២៣/០២/១២** ម៉ោង ១៥:០០ នាទី | ចូលរួមប្រជុំគណៈកម្មការព្រលានយន្តហោះ នៅព្រលានយន្តហោះអន្តរជាតិភ្នំពេញ។ |
| ១៩ | **២៧/០២/១២** ម៉ោង ០៨:៣០ នាទី | ចូលរួមជាកិត្តិយសក្នុងពិធីប្រកាសផ្សព្វផ្សាយជាផ្លូវការចលនាប្រឡងប្រណាំងទីក្រុងស្អាត ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា នៅទីស្តីការនាយករដ្ឋមន្ត្រី។ |
| ២០ | **២៨/០២/១២** ម៉ោង ០៧:៣០នាទី | ចូលរួមជាកិត្តិយសក្នុងពិធីប្រគល់សញ្ញាបត្រជូនដល់សនិស្សិតវិទ្យាស្ថានបច្ចេកវិទ្យាកម្ពុជា និងសម្ពោធដាក់ឲ្យប្រើប្រាស់សាលសហសិក្សា អគារសិក្សា **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា នៅវិទ្យាស្ថានបច្ចេកវិទ្យាកម្ពុជា។ |
| ២១ | **២៩/០២/១២** ម៉ោង ០៨:០០ នាទី | ចូលរួមជាកិត្តិយសក្នុងសន្និសីទប្រចាំឆ្នាំ របស់បណ្តាញធានាគុណភាពអាស៊ីប៉ាស៊ីហ្វិក (APQN) ឆ្នាំ២០១២ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ ឯកឧត្តម បណ្ឌិតសភាចារ្យ **សុខ អាន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី នៅសាលសន្និសីទអាង្គាធរអប្សរា ខេត្តសៀមរាប។ |

# សកម្មភាពផ្សេងទៀតរបស់ ឯកឧត្តម អនុប្រធាន និងសមាជិក ក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ ប្រចាំខែកុម្ភៈ ឆ្នាំ២០១២

## ឯកឧត្តម យឹម ណុលសន អនុប្រធាន

| ល.រ | កាលបរិច្ឆេទ | សកម្មភាព |
|---|---|---|
| ១ | ១៣/០២/១២ | ចូលរួមជាកិត្តិយសក្នុងពិធីចុះហត្ថលេខាលើកិច្ចព្រមព្រៀង រវាងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា និងអង្គការយូណេស្កូ ស្តីពីការជួសជុលប្រាសាទបាយ័ន ដំណាក់កាលទី៤ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ ឯកឧត្តម បណ្ឌិតសភាចារ្យ **សុខ អាន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី នៅទីស្តីការគណៈរដ្ឋមន្ត្រី។ |
| ២ | ១៦/០២/១២ | ចូលរួមជាកិត្តិយសក្នុងពិធីផ្ទេរ-ប្រគល់ជំនួយសម្ភារៈបច្ចេកទេសដំណាក់កាលទី៦ របស់រដ្ឋាភិបាលជប៉ុន ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ ឯកឧត្តម បណ្ឌិតសភាចារ្យ **សុខ អាន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី នៅទីបញ្ជាការដ្ឋានស៊ីម៉ាក់ ខេត្តសៀមរាប។ |
| ៣ | ២៧/០២/១២ | ចូលរួមជាកិត្តិយសក្នុងពិធីសម្ពោធអគារសិក្សាអនុវិទ្យាល័យ សុខ អាន ព្រៃកផ្គោល ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ ឯកឧត្តម បណ្ឌិតសភាចារ្យ **សុខ អាន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី នៅឃុំព្រៃកផ្គោល ស្រុកអង្គរបូរី ខេត្តតាកែវ។ |

## ឯកឧត្តម ឌុយ ធៅ អនុប្រធាន

| ល.រ | កាលបរិច្ឆេទ | សកម្មភាព |
|---|---|---|
| ១ | ១៦/០២/១២ | ចូលរួមជាកិត្តិយសក្នុងពិធីផ្ទេរ-ប្រគល់ជំនួយសម្ភារៈបច្ចេកទេសដំណាក់កាលទី៦ របស់រដ្ឋាភិបាលជប៉ុន ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ ឯកឧត្តម បណ្ឌិតសភាចារ្យ **សុខ អាន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី នៅទីបញ្ជាការដ្ឋានស៊ីម៉ាក់ ខេត្តសៀមរាប។ |
| ២ | ២៧/០២/១២ | ចូលរួមជាកិត្តិយសក្នុងពិធីសម្ពោធអគារសិក្សាអនុវិទ្យាល័យ សុខ អាន ព្រៃកផ្គោល ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ ឯកឧត្តម បណ្ឌិតសភាចារ្យ **សុខ អាន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី នៅឃុំព្រៃកផ្គោល ស្រុកអង្គរបូរី ខេត្តតាកែវ។ |

## ឯកឧត្តម ឡុង ឈាង សមាជិក

| ល.រ | កាលបរិច្ឆេទ | សកម្មភាព |
|---|---|---|
| ១ | ៩/០២/១២ | ចូលរួមប្រជុំពិភាក្សាឆ្លងសេចក្តីព្រាងរបាយការណ៍ស្តីពីសកម្មភាព និងលទ្ធផលការងារប្រចាំខែមករា ឆ្នាំ ២០១២ របស់អាជ្ញាធរជាតិដោះស្រាយទំនាស់ដីធ្លី(អ.ជ.ដ.)។ |

# សកម្មភាពដទៃទៀតរបស់ ឯកឧត្តម អគ្គលេខាធិការ ក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ ប្រចាំខែកុម្ភៈ ឆ្នាំ២០១២

## ឯកឧត្តម ង៉ាន់ ភិរុណ អគ្គលេខាធិការ

| ល.រ | កាលបរិច្ឆេទ | សកម្មភាព |
|---|---|---|
| ១ | ០៣/០២/១២ | ចូលរួមជាកិត្តិយសអម ឯកឧត្តម បណ្ឌិតសភាចារ្យ **សុខ អាន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី ដើម្បីចូលរួមស្តាប់សវនាការប្រកាសសាលដីការបស់អង្គជំនុំជម្រះតុលាការកំពូល លើសំណុំរឿង ០០១ ប្រឆាំងនឹង **កាំង ហ្គេកអ៊ាវ** ហៅ ឌុច នៅសាលសវនាការរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា។ |
| ២ | ១៣/០២/១២ | ចូលរួមជាកិត្តិយសក្នុងពិធីចុះហត្ថលេខាលើកិច្ចព្រមព្រៀង រវាងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា និងអង្គការយូណេស្កូ ស្តីពីការជួសជុលប្រាសាទបាយ័ន ដំណាក់កាលទី៤ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ ឯកឧត្តម បណ្ឌិតសភាចារ្យ **សុខ អាន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី នៅទីស្តីការគណៈរដ្ឋមន្ត្រី។ |
| ៣ | ១៤/០២/១២ | ដឹកនាំកិច្ចប្រជុំពិភាក្សាការងារជាមួយ ឯកឧត្តម អគ្គលេខាធិការរង នៃក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ នៅទីស្តីការគណៈរដ្ឋមន្ត្រី។ |
| ៤ | ១៦/០២/១២ | ចូលរួមជាកិត្តិយសក្នុងពិធីផ្ទេរ-ប្រគល់ជំនួយសម្ភារៈបច្ចេកទេសដំណាក់កាលទី៦ របស់រដ្ឋាភិបាលជប៉ុន ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ ឯកឧត្តម បណ្ឌិតសភាចារ្យ **សុខ អាន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី នៅទីបញ្ជាការដ្ឋានស៊ីម៉ាក់ ខេត្តសៀមរាប។ |
| ៥ | ២៧/០២/១២ | ចូលរួមជាកិត្តិយសក្នុងពិធីសម្ពោធអគារសិក្សាអនុវិទ្យាល័យ សុខ អាន ព្រៃកផ្គាល ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ ឯកឧត្តម បណ្ឌិតសភាចារ្យ **សុខ អាន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី នៅឃុំព្រៃកផ្គាល ស្រុកអង្គរបូរី ខេត្តតាកែវ។ |

# ពិធីចុះហត្ថលេខាលើកិច្ចសន្យាគូរប្លង់គម្រោងសាងសង់ អគារមជ្ឈមណ្ឌលព័ត៌មាន និងបច្ចេកវិទ្យានៃទីស្តីការគណៈរដ្ឋមន្ត្រី

កាលពីថ្ងៃទី៩ ខែកុម្ភៈ ឆ្នាំ២០១២ នៅទីស្តីការគណៈរដ្ឋមន្ត្រី មានពិធីចុះហត្ថលេខាមួយ លើកិច្ចសន្យាគូរប្លង់គម្រោងសាងសង់អគារមជ្ឈមណ្ឌលព័ត៌មាន និងបច្ចេកវិទ្យានៃទីស្តីការគណៈរដ្ឋមន្ត្រី ជាជំនួយរបស់សាធារណរដ្ឋប្រជាមានិតចិន ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ ឯកឧត្តម **យឹម ណុលឡា** ទេសរដ្ឋមន្ត្រីទទួលបន្ទុកបេសកកម្មពិសេស ប្រធានក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ (ECOSOCC) និងជាប្រធានគណកម្មការសម្របសម្រួលនិងសហការជាមួយភាគីចិនលើគម្រោងសាងសង់អគារមជ្ឈមណ្ឌលព័ត៌មាន និងបច្ចេកវិទ្យានៃទីស្តីការគណៈរដ្ឋមន្ត្រី ដោយមានការចូលរួមពីសំណាក់ លោក **ជិញ យាន** និងមន្ត្រីអមដំណើរ ដែលជាតំណាងការិយាល័យសេដ្ឋកិច្ច និងពាណិជ្ជកម្ម នៃស្ថានទូតសាធារណរដ្ឋប្រជាមានិតចិនប្រចាំនៅកម្ពុជា និងសមាជិកគណៈកម្មការទាំងអស់។




ឆ្លៀតក្នុងឱកាសនោះ ឯកឧត្តម **យឹម ណុលឡា** បានថ្លែងអំណរគុណចំពោះរដ្ឋាភិបាលចិន និងប្រជាជនចិន ដែលតែងតែជួយដល់ប្រទេសកម្ពុជាលើគ្រប់វិស័យ ជាពិសេសគម្រោងសាងសង់អគារមិត្តភាពនៃទីស្តីការគណៈរដ្ឋមន្ត្រី ហើយបច្ចុប្បន្ននេះបានជួយលើគម្រោងសាងសង់អគារមជ្ឈមណ្ឌលព័ត៌មាន និងបច្ចេកវិទ្យានៃទីស្តីការគណៈរដ្ឋមន្ត្រី (អគារ IT) ថែមទៀត។

គណកម្មការសម្របសម្រួល បាននឹងកំពុងសហការយ៉ាងសកម្មជាមួយក្រុមហ៊ុនសាជីវកម្មវិស្វកម្មអន្តរជាតិប្រទេសចិន (IPPR) ដែលរដ្ឋាភិបាលចិនបានជ្រើសរើសដើម្បីគូរគម្រោងប្លង់នេះ ឲ្យមានភាពទំនើប និងស្របទៅតាមរចនាបទខ្មែរផងដែរ។

អគារមជ្ឈមណ្ឌលព័ត៌មាន និងបច្ចេកវិទ្យានៃទីស្តីការគណៈរដ្ឋមន្ត្រី (អគារ IT) សម្រាប់ដាក់ស្ថាប័នចំនួន ០៣ (អគ្គលេខាធិការដ្ឋានរាជរដ្ឋាភិបាល អគ្គលេខាធិការដ្ឋាន NIDA និងអគ្គនាយកដ្ឋានរាជកិច្ច) ដែលស្ថិតនៅពីខាងក្រោយអគារមិត្តភាពនៃទីស្តីការគណៈរដ្ឋមន្ត្រី លើផ្ទៃដីទំហំ ៤៤២៥,៥៤ម៉ែត្រការ៉េ មានបណ្តោយ ៧១,៩៦ម៉ែត្រ និងទទឹង ៦១,៥០ម៉ែត្រ។ អគារនេះមានចំនួន ៨ជាន់ រួមទាំងជាន់ផ្ទាល់ដី (ពុំមានជាន់ក្រោមដីទេ) មានកម្ពស់ ៣៨,១ម៉ែត្រ (បើប្រៀបធៀបទៅនឹងអគារមិត្តភាព មានកម្ពស់ទាបជាងប្រមាណ ៣,៨ម៉ែត្រ ដោយផ្ទៃដីរបស់អគារ IT ទាបជាងអគារមិត្តភាព ២ម៉ែត្រ) បណ្តោយ ៣៨,៦ម៉ែត្រ និងទទឹង ៣៤ម៉ែត្រ ហើយអគារនេះមានផ្ទៃក្រឡាសរុប ១១,៣០០ម៉ែត្រការ៉េ និងមានចំណតរថយន្ត ៣៥កន្លែងក្រោមអគារ និងក្រៅអគារ។

# ព្រឹត្តិបត្រព័ត៌មាន

| | | |
|---|---|---|
| នាយកគ្រប់គ្រងទូទៅ: | **ឯកឧត្តម គីម សយសាម៉ាឡែន** | អនុប្រធាន ក.ស.វ. |
| និពន្ធនាយក: | **ឯកឧត្តម ថ៉ាន់ គិរុណា** | អគ្គលេខាធិការ ក.ស.វ. |
| និពន្ធអគ្គបទ: | **ឯកឧត្តម អេង វត្ថមុនី** | អគ្គលេខាធិការរង ក.ស.វ. |
| វិភាគស្ថានភាពសេដ្ឋកិច្ច: | **ឯកឧត្តម ម៉ម សារិទ្ធ** | សមាជិកបម្រុង ក.ស.វ. |
| ទំនាក់ទំនងនិងបោះពុម្ពផ្សាយ: | **លោក ម៉ក់ ឆារ៉ា** | ប្រធានផ្នែក ក.ស.វ. |
| បច្ចេកទេសកុំព្យូទ័រនិងសម្របសម្រួល: | **លោក សយ វាសា្ន** | អនុប្រធានផ្នែក ក.ស.វ. |
| យកព័ត៌មាននិងថតរូប: | **លោក មុត ភក្តដា** | មន្ត្រី ក.ស.វ. |



## ក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌


ទូរស័ព្ទលេខ: ០២៣ ២១១ ៩៤៣ ០១៦ ៣០៧ ៣៣០

ទូរសារលេខ: ០២៣ ២១១ ៩៤៣

E-mail: veasna@live.in